00945122

E127/7/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
16 / 08 / 2013
ម៉ោង (Time/Heure): 14:15
មន្ត្រីមទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ៖** សហព្រះរាជអាជ្ញាអន្តរជាតិ — ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** គ្រប់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២, លោក /លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ព័ត៌មានទាក់ទិននឹងចម្លើយសាក្សីនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២

១. សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងដល់អង្គជំនុំជម្រះអំពីចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួនដែលបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលអាចពាក់ព័ន្ធនឹងផ្នែកមួយចំនួននៃសំណុំរឿង ០០២/០១ (E127/7)។ នៅក្នុងឧបសម្ព័ន្ធសម្ងាត់បំផុតដែលភ្ជាប់មកជាមួយ សហព្រះរាជអាជ្ញាអន្តរជាតិបានសរសេរឈ្មោះសាក្សីចំនួន ១៦ រូប ដែលបានផ្តល់ចម្លើយជូន ក.ស.ច.ស និងបញ្ជាក់អំពីភាពជាប់ពាក់ព័ន្ធនៃចម្លើយសាក្សីនីមួយៗ ដែលបានលើកឡើង (E127/7.1)។ ចម្លើយរបស់សាក្សីទាំងនោះមិនបានផ្តល់មកនោះទេ។

២. អង្គជំនុំជម្រះទទួលស្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិបានអនុវត្តដោយអនុលោមតាមកាតព្វកិច្ចរបស់ខ្លួនដែលមានជាបន្តក្នុងការបង្ហាញឯកសារសម្ភារទាំងឡាយដែលខ្លួនមាន។ ឯកសារសម្ភារទាំងនេះអាចបង្ហាញពីនត្ថិភាពនៃពិរុទ្ធ ឬសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចមានឥទ្ធិពលទៅលើភាពអាចជឿជាក់បាននៃភស្តុតាង (ឯកសារ E127/4)។ ដោយសារតែសហចៅក្រមស៊ើប

អង្កេតជាអ្នកទទួលបន្ទុកសំណុំរឿង០០៣ និង ០០៤ ហើយកំណត់ហេតុស្ដាប់ចម្លើយដែលមានការពាក់ព័ន្ធស្ថិតនៅក្នុងភាពសម្ងាត់នៃដំណើរការស៊ើបអង្កេត ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតត្រូវតែសម្រេចជាមុនសិន ថាតើអនុញ្ញាតិផ្ដល់នូវកំណត់ហេតុស្ដាប់ចម្លើយទាំងនេះមកអង្គជំនុំជម្រះដែរឬទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់សំណើនេះដោយផ្ទាល់ជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឱ្យផ្ដល់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីទាំងនេះ ។ បន្ទាប់មកអង្គជំនុំជម្រះនឹងសម្រេចថាតើត្រូវដាក់ឯកសារសម្ភារៈដែលទទួលបានពី ក.ស.ច.ស នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧ ដែរឬយ៉ាងណា។